ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
**Ministry of Industry, Mines and Energy**
N° ៧៧១ ឧរថ-សឧក.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌទូទៅនៃការផ្តល់អាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល

---

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីស្តង់ដាឧស្សាហកម្មកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការតម្លើងការិយាល័យអាស៊ាន និងការិយាល័យស្តង់ដាឧស្សាហកម្មទៅជានាយកដ្ឋានសហប្រតិបត្តិការនិងការងារអាស៊ាន និងជានាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជានៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- យោងទៅតាមតម្រូវការជាក់ស្តែង

## សម្រេច

**ប្រការ ១** : កំណត់លក្ខខណ្ឌទូទៅនៃការផ្តល់អាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផលសំរាប់អនុវត្តក្នុងការបញ្ជាក់ផលិតផលដែលប្រតិបត្តិដោយនាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ២ :** សញ្ញាបញ្ជាក់ផលិតផលគឺជាសញ្ញាស្តង់ដាឧស្សាហកម្មកម្ពុជា ដែលបញ្ជាក់ពីការអនុលោមតាមការតំរូវនៃស្តង់ដាឧស្សាហកម្មកម្ពុជា ដូចដែលបានកំណត់នៅក្នុងប្រកាសលេខ១១២ ឧរថ.សឧក.ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីអំពីសញ្ញាសំគាល់ស្តង់ដាឧស្សាហកម្មកម្ពុជា ។

**ប្រការ ៣ :** ការស្នើសុំ

១- រាល់ការស្នើសុំអាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល ត្រូវដាក់សំណើទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដោយត្រូវបំពេញទំរង់បែបបទដូចមាននៅក្នុង **ឧបសម្ព័ន្ធ ១** ។

២-នៅពេលទទួលពាក្យស្នើសុំ នាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា ត្រូវចាត់មន្ត្រីមានសមត្ថកិច្ចឱ្យចុះពិនិត្យដល់ទីកន្លែង និងតំរូវឱ្យអ្នកស្នើសុំ :

ក- បង្ហាញភស្តុតាងដែលអាចទទួលយកបានដោយនាយកដ្ឋានគឺ :

- ផលិតផល ឬដំណើរការផលិតកម្មដែលត្រូវស្នើសុំអាជ្ញាប័ណ្ណបានអនុលោមទៅតាមស្តង់ដាឧស្សាហកម្មកម្ពុជាណាមួយ
- ប្រព័ន្ធធានាគុណភាពមួយ ដែលធានាបានយ៉ាងគ្រប់គ្រាន់ថា ផលិតផល ឬដំណើរការផលិតកម្មដែលត្រូវស្នើសុំអាជ្ញាប័ណ្ណ នឹងបន្តអនុលោមទៅតាមស្តង់ដានោះ

ខ- បង្ហាញគ្រប់សម្ភារៈបរិក្ខាប្រើប្រាស់ទាំងអស់ដល់មន្ត្រីមានសមត្ថកិច្ចនៅគ្រប់កន្លែងទាំងអស់របស់អ្នកស្នើសុំសំរាប់ :

- ធ្វើការផ្ទៀងផ្ទាត់នូវភស្តុតាងដែលផ្តល់ឱ្យដោយអ្នកស្នើសុំ
- ធ្វើការត្រួតពិនិត្យបែបផែននិងដំណើរការផលិតកម្ម និងការកត់ត្រាទាំងអស់ដែលពាក់ព័ន្ធទៅនឹងផលិតផលនោះ
- ទទួលយកពត៌មានផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងការស្នើសុំ

គ- ផ្តល់គំរូផលិតផលសំរាប់ធ្វើតេស្ត ។

**ប្រការ ៤ :** ចាប់ពីបានទទួលពាក្យស្នើសុំស្របតាមប្រការ៣ ប្រសិនបើនាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជាបានពិនិត្យឃើញថា ផលិតផលនោះបានអនុលោមតាមស្តង់ដាណាមួយហើយ នាយកដ្ឋានត្រូវជូនដំណឹងដល់អ្នកស្នើសុំដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងប្រើសញ្ញាបញ្ជាក់ផលិតផល រួចចេញវិញ្ញាបនប័ត្រអនុលោមស្តង់ដាដូចមានគំរូនៅក្នុង **ឧបសម្ព័ន្ធ ២**។

យោងវិញ្ញាបនប័ត្រអនុលោមស្តង់ដារនេះ ក្រសួងត្រូវផ្តល់អាជ្ញាប័ណ្ណ ដូចមានគំរូនៅក្នុងឧបសម្ព័ន្ធ ៣ ដល់អ្នកស្នើសុំ ដើម្បីបានប្រើប្រាស់សញ្ញាបញ្ជាក់ផលិតផលតាមកាលកំណត់ និងលក្ខខណ្ឌដូចខាងក្រោម :

១- អាជ្ញាប័ណ្ណមិនត្រូវបានផ្តល់ជូនឡើយ លុះត្រាតែបានបង់កំរៃអាជ្ញាប័ណ្ណ ដែលបានបញ្ជាក់នៅក្នុងប្រកាសរួមរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបង់កំរៃអាជ្ញាប័ណ្ណ ។

២- វិសាលភាពនៃអាជ្ញាប័ណ្ណ នឹងគ្របដណ្តប់ទៅលើផលិតផល ឬទំនិញ ដែលបានកែច្នៃផលិតនៅក្នុងរោងចក្រ/ទីកន្លែងផលិតដែលបានចែងនៅក្នុងអាជ្ញាប័ណ្ណ និងមានពាណិជ្ជសញ្ញា/ពាណិជ្ជនាមដែលបានចុះនៅក្នុងអាជ្ញាប័ណ្ណ ព្រមទាំងមានបញ្ជាក់អំពីប្រភេទ ទំហំ រសជាតិ គំរូ ។ល ។នៅក្នុងលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ។

៣- ហាមធ្វើចរាចរនិងលក់ផលិតផល ឬទំនិញដែល :

- មិនបានបំពេញទៅតាមវិសាលភាពនៃស្តង់ដាមួយដូចបានចែងនៅក្នុងអាជ្ញាប័ណ្ណ ហើយមិនមានប្រើសញ្ញាបញ្ជាក់ផលិតផល
- ប្រើសញ្ញាបញ្ជាក់ផលិតផល តែមិនអនុលោមទៅតាមការតំរូវនៃស្តង់ដា និង
- ផលិតនៅក្នុងរោងចក្រ ឬកន្លែងផលិតណាមួយដែលខុសពីរោងចក្រ ឬកន្លែងផលិត ដែលបានចុះនៅក្នុងអាជ្ញាប័ណ្ណ លើកលែងតែរោងចក្រ ឬ កន្លែងផលិតនោះបានទទួលការអនុញ្ញាតដោយឡែកណាមួយ ។

៤- ក្នុងករណីដែលអ្នកកាន់អាជ្ញាប័ណ្ណផលិតផលិតផលដូចគ្នាណាមួយ ដែលមានប្រភេទ ទំហំ រសជាតិ គំរូ ។ល ។ផ្សេងពីការចែងនៅក្នុងលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ហើយស្ថិតនៅក្នុងវិសាលភាពនៃស្តង់ដាដូចគ្នានោះ ប្រភេទ ទំហំ រសជាតិ គំរូ ។ល ។ទាំងនោះនៃផលិតផលត្រូវតែអនុលោមតាមស្តង់ដាដែលបានកំណត់ និងត្រូវអនុវត្តតាមលក្ខខណ្ឌអាជ្ញាប័ណ្ណ ។

៥- អ្នកកាន់អាជ្ញាប័ណ្ណត្រូវតែផ្តល់ពត៌មានជាលាយលក្ខណ៍អក្សរភ្លាមទៅក្រសួងអំពីប្រភេទ ទំហំ រសជាតិ គំរូ ។ល ។នៃផលិតផលដែលបានយោងនៅក្នុងចំណុច ៤ ខាងលើ ។

៦- នៅពេលអាជ្ញាប័ណ្ណត្រូវបានផ្តល់ដោយយោងទៅតាមទីកន្លែងកែច្នៃ ដំណើរការផលិតកម្ម ប្រព្រឹត្តកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងប្រសិនបើផលិតផលដូចគ្នា បិទពាណិជ្ជសញ្ញា ឬពាណិជ្ជនាមដូចគ្នាដែលបាននាំចូល ផលិតផលនាំចូលទាំងនោះមិនស្ថិតនៅក្នុងវិសាលភាពនៃអាជ្ញាប័ណ្ណទេ ។ ផលិតផលទាំងឡាយណាដែលស្ថិតនៅក្នុងវិសាលភាព នៃអាជ្ញាប័ណ្ណ

ត្រូវតែបែងចែកឱ្យច្បាស់លាស់ដាច់ពីផលិតផលនាំចូល ដោយយោងទៅតាមរបៀបមួយដែលបានបញ្ជាក់នៅក្នុងលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ។

៧- អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំកម្មវិធីគ្រប់ករណីចាំបាច់ សំរាប់នាយកដ្ឋានធ្វើសវនកម្មលើប្រព័ន្ធធានាគុណភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណ និងធ្វើការត្រួតពិនិត្យ ធ្វើអធិការកិច្ច និងធ្វើការផ្ទៀងផ្ទាត់លើភាពអនុលោមទាំងអស់ទៅតាមលក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណនេះ និងទៅតាមលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ។

៨- ក្នុងករណីដែលការកែច្នៃ ដំណើរការផលិត ប្រព្រឹត្តកម្មនៃផលិតផល ឬទំនិញត្រូវបានជួលបន្តដោយអ្នកកាន់អាជ្ញាប័ណ្ណ អ្នកកាន់អាជ្ញាប័ណ្ណត្រូវទទួលខុសត្រូវដូចខាងក្រោម :

ក) ធានាថា អ្នកជួលបន្តបានអនុលោមទៅតាមលក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណនេះ និងទៅតាមលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ

ខ) រៀបចំជាមួយអ្នកជួលបន្ត សំរាប់ឱ្យនាយកដ្ឋានធ្វើសវនកម្មលើប្រព័ន្ធធានាគុណភាពរបស់អ្នកជួលបន្ត និងធ្វើការត្រួតពិនិត្យ ធ្វើអធិការកិច្ច និងធ្វើការផ្ទៀងផ្ទាត់លើភាពអនុលោមទៅតាមលក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណនេះ និងទៅតាមលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ។

៩- អាជ្ញាប័ណ្ណ :

ក) នឹងត្រូវបានផ្តល់ឱ្យចំពោះផលិតផលដែលមានពាណិជ្ជសញ្ញា ឬពាណិជ្ជនាម

ខ) នឹងត្រូវបានផ្តល់ឱ្យចំពោះស្តង់ដានីមួយៗ និងចំពោះរោងចក្រនីមួយៗ

គ) នឹងត្រូវមានសុពលភាពក្នុងរយៈពេលបីឆ្នាំ គិតពីថ្ងៃដែលផ្តល់ឱ្យ និង

ឃ) អាចត្រូវបានផ្តល់ឱ្យសារជាថ្មី ដោយអ្នកកាន់អាជ្ញាប័ណ្ណត្រូវធ្វើសំណើទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានសាមសិបថ្ងៃមុនថ្ងៃផុតកំណត់សុពលភាពរបស់អាជ្ញាប័ណ្ណ និងមានការបង់កំរៃអាជ្ញាប័ណ្ណ ។

១០- ក្រសួងអាចផ្តល់អាជ្ញាប័ណ្ណទុតិយតាឱ្យអ្នកកាន់អាជ្ញាប័ណ្ណ នៅពេលដែលបានបង្ហាញហេតុផលសមរម្យថា អាជ្ញាប័ណ្ណត្រូវបានខូច រហែក ឬបាត់បង់ ។

**ប្រការ ៥:** ការពិនិត្យអង្កេត

ការពិនិត្យអង្កេតផលិតផលលើមូលដ្ឋាននៃការតំរូវរបស់ស្តង់ដាពាក់ព័ន្ធ និងប្រព័ន្ធធានាគុណភាពដែលបានបញ្ជាក់នៅក្នុងលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណ ត្រូវទទួលរ៉ាប់រងធ្វើដោយនាយកដ្ឋាន

ស្តង់ដាឧស្សាហកម្មកម្ពុជា ។ នាយកដ្ឋានត្រូវផ្តល់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណនូវលទ្ធផលនៃការពិនិត្យអង្កេតនេះ ។

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្តល់ពត៌មានទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលវិញនូវរាល់ការកែប្រែណាមួយក្នុងផលិតផល ដំណើរការផលិតកម្ម ឬប្រព័ន្ធធានាគុណភាព ដែលអាចមានឥទ្ធិពលទៅលើភាពអនុលោមនៃផលិតផល ។ ក្នុងករណីបែបនេះ អ្នកកាន់អាជ្ញាប័ណ្ណមិនអាចបញ្ចេញផលិតផលដែលមានបិទសញ្ញាបញ្ជាក់ផលិតផល ដែលជាលទ្ធផលចេញមកពីការកែប្រែទាំងនោះបានទេ លុះត្រាតែមានការយល់ព្រមពីក្រសួងជាមុនសិន ។

អ្នកកាន់អាជ្ញាប័ណ្ណត្រូវរក្សាទុកឯកសារកត់ត្រានៃការតវ៉ាទាំងអស់ ដែលទាក់ទងទៅនឹងផលិតផលដែលបានទទួលអាជ្ញាប័ណ្ណ និងត្រូវមានឯកសារនោះសំរាប់នាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា បើមានសំណូមពរ ។

**ប្រការ ៦:** ការព្យួរទុក និង ការដកហូតអាជ្ញាប័ណ្ណ

១- អាជ្ញាប័ណ្ណដែលអនុវត្តចំពោះផលិតផលជាក់លាក់មួយ អាចត្រូវបានព្យួរទុកក្នុងរយៈពេលមួយមិនលើសពីបីខែក្នុងមួយលើក ប្រសិនបើ :

ក) មិនបានប្រតិបត្តិតាម លក្ខខណ្ឌអាជ្ញាប័ណ្ណ

ខ) ប្រើប្រាស់អាជ្ញាប័ណ្ណ ឬសញ្ញាអនុលោមមិនបានត្រឹមត្រូវ ដោយការបោះពុម្ព ឬការផ្សព្វផ្សាយមិនបានត្រឹមត្រូវ ហើយមិនបានចាត់វិធានការដោះស្រាយ ឬកែតំរូវឱ្យបានទាន់ពេលវេលា

គ) បានប្រើសញ្ញាបញ្ជាក់ផលិតផលលើផលិតផល ឬដំណើរការផលិតកម្ម ដែលមិនអនុលោមតាមស្តង់ដាកំណត់ពាក់ព័ន្ធ

ឃ) មិនបានផ្តល់សម្ភារៈបរិក្ខាដែលប្រើសំរាប់ធ្វើអធិការកិច្ច ឬគំរូផលិតផលសំរាប់ធ្វើតេស្ត

ង) រំលោភទៅនឹងបទបញ្ញត្តិណាមួយនៃអនុក្រឹត្យលេខ ៤ ២អនក្រ.បក ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីស្តង់ដាឧស្សាហកម្មកម្ពុជា ប្រកាស ឬបទបញ្ជាពាក់ព័ន្ធ ។

២- អាជ្ញាប័ណ្ណអាចត្រូវបានដកហូតនៅពេលដែលបានរកឃើញថា អ្នកកាន់អាជ្ញាប័ណ្ណ :

ក) អនុវត្តខុសធ្ងន់ធ្ងរទៅនឹងការតំរូវនៃលក្ខខណ្ឌអាជ្ញាប័ណ្ណ

ខ) មិនបានបំពេញលក្ខខណ្ឌទាំងឡាយដែលបានតំរូវឱ្យធ្វើការកែតំរូវក្នុងពេលព្យួរទុក

គ) បានប្រព្រឹត្តកំហុសដូចគ្នាទៅនឹងកំហុសដែលនាំឱ្យមានការព្យួរទុកលើកមុន ក្នុងរយៈពេលបីឆ្នាំកន្លងមក ។

៣- អ្នកកាន់អាជ្ញាប័ណ្ណនឹងត្រូវបានទទួលដំណឹង ដប់ប្រាំថ្ងៃមុនពេលព្យួរទុក ឬដកហូតអំពីបំណង និងមូលហេតុដែលនាំឱ្យមានការព្យួរទុក ឬដកហូត

៤- នៅពេលអាជ្ញាប័ណ្ណត្រូវបានព្យួរទុក ឬដកហូត អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវបញ្ជាក់តាមរូបភាពណាមួយបង្ហាញថា ផលិតផលនោះមានអាជ្ញាប័ណ្ណទេ ហើយត្រូវតែផ្អាកភ្លាមនូវការប្រើសញ្ញាបញ្ជាក់ផលិតផលនោះ និងត្រូវ :

- ចាត់វិធានការចាំបាច់ដកសញ្ញាបញ្ជាក់ផលិតផលចេញ ឬលុបចោលចេញពីផលិតផល
- ប្រគល់អាជ្ញាប័ណ្ណមកក្រសួងវិញ ។

៥-ប្រសិនបើនៅពេលណាមានការលំបាកក្នុងការរក្សាផលិតផលឱ្យអនុលោមបានទៅតាមស្តង់ដា ឬមួយសម្ភារៈធ្វើតេស្តខូចប្រើការមិនកើត ត្រូវផ្តល់ដំណឹងទៅក្រសួងឱ្យបានដឹង ឬប្រសិនបើមានការបញ្ជាឱ្យព្យួរទុកដោយក្រសួងសំរាប់ហេតុផលណាមួយ ការដាក់សញ្ញាបញ្ជាក់ផលិតផលលើផលិតផលត្រូវតែបញ្ឈប់ ។ ការដាក់សញ្ញាបញ្ជាក់ផលិតផលអាចអនុវត្តសារជាថ្មីឡើងវិញភ្លាម នៅពេលបញ្ហាទាំងអស់ត្រូវបានដោះស្រាយ ឬនៅពេលដែលក្រសួងអនុញ្ញាតឱ្យប្រើសញ្ញាបញ្ជាក់ផលិតផលឡើងវិញ ។ ការចាប់ផ្តើមប្រើសញ្ញាបញ្ជាក់ផលិតផលសារជាថ្មីត្រូវផ្តល់ដំណឹងទៅក្រសួង ។

៦-ប្រសិនបើការផលិតផលិតផលត្រូវបានបញ្ឈប់រហូតក្នុងរយៈពេលប្រាំមួយខែត្រូវ ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួង ហើយសញ្ញាបញ្ជាក់ផលិតផលត្រូវព្យួរទុកសិន ។ នៅពេលដំណើរការផលិតឡើងវិញ ត្រូវតែមានការវាយតំលៃសារជាថ្មីដោយនាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា មុនពេលអនុម័តឱ្យប្រើសញ្ញាបញ្ជាក់ផលិតផលសារជាថ្មី ។

**ប្រការ ៧:** ការបិទសញ្ញាបញ្ជាក់ផលិតផល

អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ :

ក) ត្រូវបិទសញ្ញាបញ្ជាក់ផលិតផលលើផលិតផល ឬលើសម្ភារៈវេចខ្ចប់ផលិតផលក្នុងរបៀបមួយដែលងាយស្រួលមើលឃើញ

ខ) ត្រូវបិទបន្ថែមលេខស្តង់ដានិងលេខកូដភ្ជាប់នឹងសញ្ញាបញ្ជាក់ផលិតផល ក្នុងរបៀបមួយដែលងាយស្រួលមើលឃើញពីក្រោម ឬពីចំហៀងនៃសញ្ញាបញ្ជាក់ផលិតផលនោះ

គ) មិនត្រូវផ្ទេរការប្រើប្រាស់សញ្ញាបញ្ជាក់ផលិតផលពីផលិតផលមួយទៅផលិតផលមួយផ្សេងទៀតឡើយ ។

**ប្រការ ៨:** ការផ្សព្វផ្សាយរបស់អ្នកកាន់អាជ្ញាប័ណ្ណ

អ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិផ្សព្វផ្សាយថា ខ្លួនត្រូវបានទទួលសិទ្ធិប្រើសញ្ញាបញ្ជាក់ផលិតផលសំរាប់ផលិតផលទាំងឡាយណាដែលមានចុះនៅក្នុងអាជ្ញាប័ណ្ណ ។

ក្នុងគ្រប់ករណីអ្នកកាន់អាជ្ញាប័ណ្ណត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះការបោះផ្សាយ និងផ្សព្វផ្សាយពាណិជ្ជកម្មថា គ្មានការភាន់ច្រឡំកើតឡើងទេ រវាងផលិតផលមានអាជ្ញាប័ណ្ណ និង ផលិតផលគ្មានអាជ្ញាប័ណ្ណ ។

អ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវពោលអះអាង ឬផ្សព្វផ្សាយពត៌មាន ដែលអាចធ្វើឱ្យអ្នកទិញ ភាន់ច្រឡំជឿថា ការប្រើប្រាស់ផលិតផលបានស្ថិតនៅក្រោមការបញ្ជាក់ផលិតផល ដែលខុសពីខ្លឹមសារនៃការផ្តល់អាជ្ញាប័ណ្ណ ។ សៀវភៅណែនាំ ឬពត៌មានអំពីការប្រើប្រាស់ផ្សេងៗទៀតដែលមានភ្ជាប់ជាមួយផលិតផល និងជាប់ទាក់ទិនទៅនឹងប្រព័ន្ធចេញវិញ្ញាបនប័ត្រ ត្រូវតែមានការអនុម័តពីនាយកដ្ឋានជាមុនសិន ប្រសិនបើមានការតំរូវដោយលក្ខខណ្ឌជាក់លាក់នៃអាជ្ញាប័ណ្ណនោះ ។

**ប្រការ ៩:** ការរក្សាការសំងាត់

នាយកដ្ឋានជាអ្នកទទួលខុសត្រូវក្នុងការធានាថា មន្ត្រីនិងភ្នាក់ងាររបស់ខ្លួនត្រូវតែរក្សាឱ្យបាននូវការសំងាត់ដែលពាក់ព័ន្ធទៅនឹងពត៌មានសំងាត់ទាំងអស់ ដែលបានដឹងដោយសារលទ្ធផលនៃការទំនាក់ទំនងជាមួយអ្នកកាន់អាជ្ញាប័ណ្ណ ។

**ប្រការ ១០:** ភាពអនុលោម

១- អ្នកកាន់អាជ្ញាប័ណ្ណត្រូវ :

ក) ធានាថា ផលិតផល ឬដំណើរការផលិតកម្មដែលប្រើសញ្ញាបញ្ជាក់ផលិតផលបានអនុលោមតាមស្តង់ដាកំណត់គ្រប់ពេលវេលា

ខ) បង្កើត រក្សាទុក និងរៀបចំឯកសារប្រព័ន្ធធានាគុណភាពដែលអាចអនុវត្តបានទៅលើផលិតផល ឬ ដំណើរការផលិតកម្មដែលពាក់ព័ន្ធ

គ) ថែរក្សាឯកសារកត់ត្រាពេញលេញ និងបង្កើតថ្មីលើប្រព័ន្ធត្រួតពិនិត្យ ក្នុងគោលបំណងធ្វើឱ្យការត្រួតពិនិត្យនេះមានស្ថេរភាពរហូត

ឃ) ផ្តល់ភាពងាយស្រួលដល់ការធ្វើអធិការកិច្ចតាមតំរូវការរបស់មន្ត្រីមានសមត្ថកិច្ចនូវឯកសារនិងការកត់ត្រាយោងទាំងឡាយនៅក្នុងចំណុច ខ និង គ ខាងលើនេះ

ង) អនុញ្ញាតឱ្យយកនូវឯកសារ ឬការកត់ត្រាចេញពីកន្លែងរបស់ខ្លួនទៅក្រសួង សំរាប់ការពិនិត្យឱ្យបានម៉ត់ចត់ ។

២- ការរៀបចំនូទៅសំរាប់ការធ្វើតេស្ត

ក) ការធ្វើតេស្ត និងការធ្វើអធិការកិច្ចដែលបានបញ្ជាក់នៅក្នុងផែនការគុណភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវតែធ្វើឡើងដោយអ្នកកាន់អាជ្ញាប័ណ្ណ ដោយប្រើប្រាស់ឧបករណ៍ធ្វើតេស្តផ្ទាល់ខ្លួនក៏បាន និង/ឬ តាមរយៈនាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជាក៏បាន និង/ឬ តាមរយៈមន្ទីរពិសោធន៍ផ្សេងទៀតដែលបានទទួលស្គាល់ជាផ្លូវការក៏បាន ។

ខ) ប្រសិនបើក្រសួងបង្ហាញពីបំណងនៃការផ្លាស់ប្តូរ ឬការប្រែប្រួលក្នុងរបៀបណាមួយសំរាប់ការធ្វើតេស្ត និងសំរាប់ការត្រួតពិនិត្យគុណភាពផលិតផលដែលជាការចាំបាច់ ក្រសួងត្រូវផ្តល់ដំណឹងយ៉ាងតិចបីខែមុនការផ្លាស់ប្តូរ ឬការប្រែប្រួលនេះ ។

គ) ការផ្លាស់ប្តូរ ឬការប្រែប្រួលនេះ ត្រូវតែជាភារកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណរហូតដល់ផុតសុពលភាពដែលបានកំណត់ យោងទៅតាមលក្ខខណ្ឌ ២ ខ ខាងលើ ដែលបានបញ្ជាក់ថា អ្នកកាន់អាជ្ញាប័ណ្ណត្រូវតែទទួលយកនូវការផ្លាស់ប្តូរ ឬការប្រែប្រួលក្នុងការរៀបចំសំរាប់ការធ្វើតេស្ត និងការត្រួតពិនិត្យគុណភាពផលិតផលមុនរយៈពេលផុតកំណត់ខាងលើ ។

ឃ) មន្ត្រីមានសមត្ថកិច្ចរបស់នាយកដ្ឋាន អាចយកគំរូផលិតផលនៅតាមទីផ្សារ ឬទីកន្លែងផលិតរបស់អ្នកកាន់អាជ្ញាប័ណ្ណសំរាប់ការធ្វើតេស្ត និង/ឬការធ្វើអធិការកិច្ច ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវតែបង់ថ្លៃចំណាយទាំងអស់លើការយកគំរូផលិតផលខាងលើនេះ ។

ង) អ្នកកាន់អាជ្ញាប័ណ្ណត្រូវរៀបចំផលិតផលជាឡូត៍ ហើយសម្ភារៈផ្សេងៗ ឬសម្ភារៈវេចខ្ចប់ដែលបានប្រើប្រាស់ប្រសិនបើមាន ត្រូវតែបានគូសជាសញ្ញាតាមរបៀបមួយដែលអាចទទួលយកបានដោយនាយកដ្ឋាន ដើម្បីឱ្យគំរូផលិតផលនីមួយៗអាចតាមដានបានទៅលើឡូត៍របស់វា ។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវតែផ្តល់ឱ្យនាយកដ្ឋាននូវនិយមន័យនៃឡូត៍ របៀបលំអិតនៃការធ្វើអត្តសញ្ញាណរបស់ឡូត៍ដែលបានកត់ចំណាំប្រព័ន្ធលេខកូដនៃអត្តសញ្ញាណរបស់ឡូត៍ជាដើម ។

៣- ឯកសារកត់ត្រាការធ្វើតេស្ត

ក) អ្នកកាន់អាជ្ញាប័ណ្ណត្រូវរក្សាទុកឯកសារកត់ត្រាគុណភាពដូចដែលបានតំរូវ ទៅតាមការតំរូវនៃប្រព័ន្ធធានាគុណភាព ដើម្បីបំពេញតាមការតំរូវរបស់នាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា ដែលផលិតកម្ម ឬដំណើរការផលិតកម្មត្រូវបាននិងកំពុងតែត្រូវបានថែរក្សាទុក

យ៉ាងត្រឹមត្រូវ ។ ឯកសារកត់ត្រាទាំងនោះ ត្រូវរៀបចំធ្វើទៅតាមយកដ្ឋានតាមសំណើសំរាប់ការធ្វើអធិការកិច្ច ។

ខ) ឯកសារកត់ត្រាដោយឡែក ត្រូវតែរក្សាទុកដើម្បីផ្តល់ពត៌មានដែលទាក់ទងទៅនឹងការមិនទទួលស្គាល់ផលិតផលនៃឡូត៍ទាំងឡាយណាដែលមិនអនុលោមតាមស្តង់ដា និងវិធីបញ្ចេញកាកសំណល់ និង/ឬ ការប្រើប្រាស់ឡើងវិញនូវកាកសំណល់របស់ផលិតផលទាំងនោះ ។

**ប្រការ ១១:** ការជំនួស

រាល់ពេលមានការតវ៉ាត្រឹមត្រូវណាមួយលើផលិតផលដែលខូច ផលិតផលនោះត្រូវតែបានជំនួសដោយផលិតផលថ្មី ហើយអ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវគិតថ្លៃលើផលិតផលថ្មីនោះឡើយ ។

សិទ្ធិអំណាចចុងក្រោយក្នុងការសំរេចភាពត្រឹមត្រូវនៃការតវ៉ា ត្រូវធ្វើឡើងដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ១២:** ការលុបចោលអាជ្ញាប័ណ្ណ

អាជ្ញាប័ណ្ណមួយត្រូវបានលុបចោលនៅពេលដែល

១- អ្នកកាន់អាជ្ញាប័ណ្ណបញ្ឈប់ដំណើរការផលិតកម្មរបស់ខ្លួន

២- អ្នកកាន់អាជ្ញាប័ណ្ណស្នើសុំឈប់បិទសញ្ញាបញ្ជាក់ផលិតផលនៅលើផលិតផលរបស់ខ្លួន

៣- មានសេចក្តីជូនដំណឹង ឬប្រកាសដែលកំណត់អំពីស្តង់ដាថ្មីមួយ ការកែប្រែ ឬការដកហូតស្តង់ដា ដែលទាក់ទិនទៅនឹងប្រភេទផលិតផលទាំងនោះចូលជាធរមាន ។

**ប្រការ ១៣ :** នៅពេលដែលអ្នកកាន់អាជ្ញាប័ណ្ណមានបំណងឈប់ប្រើប្រាស់សញ្ញាបញ្ជាក់ផលិតផល ហើយជាមួយគ្នានោះដែរ មានបំណងបោះបង់ចោលអាជ្ញាប័ណ្ណរបស់ខ្លួន អ្នកកាន់អាជ្ញាប័ណ្ណត្រូវសរសេរជាលាយលក្ខណ៍អក្សរជូនដំណឹងបញ្ជាក់ពីមូលហេតុទៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ គ្មានការសងវិញទាំងស្រុង ឬចំណែកណាមួយនៃកំរៃអាជ្ញាប័ណ្ណដែលបានបង់នោះឡើយ។ ការបោះបង់ចោលអាជ្ញាប័ណ្ណត្រូវបានចាត់ទុកថា ជាការបញ្ឈប់ការប្រើប្រាស់សញ្ញាបញ្ជាក់ផលិតផល ចាប់ពីថ្ងៃចុងក្រោយបង្អស់នៃខែដែលបានទទួលសេចក្តីសំរេចជាផ្លូវការរបស់ក្រសួង ហើយអ្នកកាន់អាជ្ញាប័ណ្ណត្រូវបានតំរូវឱ្យឈប់ប្រើតទៅទៀតនូវសញ្ញាបញ្ជាក់ផលិតផលនៅលើ ផលិតផលទាំងនោះ ។

**ប្រការ ១៤ :** ក្នុងករណីមានការកំណត់ស្តង់ដាថ្មីមួយ ឬមានការកែប្រែស្តង់ដា អ្នកកាន់អាជ្ញាប័ណ្ណដែលមានបំណងអនុលោមតាមស្តង់ដាថ្មី ឬស្តង់ដាដែលមានការកែប្រែនោះ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណឱ្យបានមុនកាលបរិច្ឆេទចូលជាធរមាននៃស្តង់ដាថ្មី ឬស្តង់ដាដែលបានកែប្រែនោះ ។ បន្ទាប់ពីបានដាក់ពាក្យស្នើសុំរួច អ្នកកាន់អាជ្ញាប័ណ្ណអាចបន្តដំណើរការរបស់ខ្លួននៅក្រោមអាជ្ញាប័ណ្ណនិងស្តង់ដាចាស់ក្នុងរយៈពេលមួយដែលបានកំណត់ដោយនាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា គឺមិនលើសពីមួយឆ្នាំគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃស្តង់ដាថ្មី ឬស្តង់ដាដែលបានកែប្រែ ។

**ប្រការ ១៥ :** ប្រកាស ឬ សេចក្តីសំរេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៦ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**

**ស៊ុយ សែម**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ( ដើម្បីគោរពជូនជ្រាប )
- ក្រសួងយុត្តិធម៌
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងព័ត៌មាន
- គ្រប់មន្ទីរឧស្សាហកម្មរ៉ែនិងថាមពលខេត្ត-ក្រុង (ដើម្បីជ្រាប)
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ ១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យស្នើសុំវិញ្ញាបនប័ត្រ និងអាជ្ញាប័ណ្ណប្រើសញ្ញាបញ្ជាក់ផលិតផល

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................អាយុ..........ឆ្នាំ សញ្ជាតិ..................ឋានៈ..................................

ក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម..................................................................................................

មានអាសយដ្ឋាន: ផ្ទះលេខ..............................ផ្លូវ/វិថី..............................ភូមិ/ក្រុម..................................................

ឃុំ/សង្កាត់ ..................................ស្រុក / ខ័ណ្ឌ ......................................ខេត្ត / ក្រុង..............................................

ទូរស័ព្ទលេខ............................................................ អ៊ីម៉ែល / Email: .........................................................................

<u>សូមគោរពជូន</u>

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

<u>កម្មវត្ថុ</u>: សំណើសុំវិញ្ញាបនប័ត្រ និង អាជ្ញាប័ណ្ណប្រើសញ្ញាស្តង់ដា : ☐ចុះបញ្ជីផលិតផល ☐បញ្ជាក់ផលិតផល ☐បញ្ជាក់សុវត្ថិភាព

ដែលប្រើពាណិជ្ជសញ្ញា. .........................................................................................................

ផលិតចេញពីក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម .................................................................

អាសយដ្ឋានផលិតកម្ម ........................... ផ្លូវ/វិថី.................. ក្រុម/ភូមិ .......................................

ឃុំ/សង្កាត់ ........................................ ស្រុក/ខណ្ឌ ..............................ខេត្ត/ក្រុង ..........................................

ទូរស័ព្ទលេខ........................................... អ៊ីម៉ែល / Email: ....................................................................

| សេចក្តីអធិប្បាយអំពីផលិតផល<br>(១) | ស្តង់ដាពាក់ព័ន្ធ<br>(២) | គោលការណ៍ និងលក្ខខណ្ឌពាក់ព័ន្ធ<br>(៣) |
|---|---|---|
| ........................................<br>........................................<br>........................................<br>........................................<br>........................................<br>........................................<br>........................................<br>........................................<br>........................................<br>........................................ | ........................................<br>........................................<br>........................................<br>........................................<br>........................................<br>........................................<br>........................................<br>........................................<br>........................................<br>........................................ | ១- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០០១ ស្តីពីស្តង់ដាឧស្សាហកម្មកម្ពុជា<br>២- CS 002:2001 (គោលការណ៍ទូទៅនៃប្រព័ន្ធចេញវិញ្ញាបនប័ត្របញ្ជាក់ផលិតផលដោយភាគីទី៣)<br>៣- ប្រកាសស្តីពីលក្ខខណ្ឌទូទៅនៃការផ្តល់អាជ្ញាប័ណ្ណសំរាប់ប្រើសញ្ញាបញ្ជាក់ផលិតផល<br>៤- កិច្ចព្រមព្រៀងអាជ្ញាប័ណ្ណ<br>៥- លក្ខខណ្ឌជាក់លាក់ |

**<u>ជូនភ្ជាប់មកជាមួយនូវ:</u>**

(១) ប្រកាស/សេចក្តីសំរេច អនុញ្ញាតបើកក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (ថតចម្លង)

(២) គំនូសបំព្រួញខ្សែសង្វាក់ផលិតកម្ម

(៣) បញ្ជីរាយឈ្មោះ គ្រឿងចក្រ-ម៉ាស៊ីន និងឧបករណ៍ប្រើប្រាស់ក្នុងការផលិត

(៤) បញ្ជីរាយឈ្មោះវត្ថុធាតុដើម ដែលប្រើប្រាស់ក្នុងការផលិត

(៥) គំរូស្លាកសញ្ញាដែលមានបំណងប្រើប្រាស់សញ្ញាស្តង់ដា

(៦) វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជសញ្ញានៃផលិតផល (ប្រសិនបើមាន)

(៧) វិញ្ញាបនប័ត្រពី GS1 CAMBODIA (ប្រសិនបើមាន)

(៨) ឯកសារដែលទាក់ទងទៅនឹង (១) (២) (៣) ឬ (៤) ឬឯកសារផ្សេងៗទៀត ។

***<u>ខ្ញុំបាទ/នាងខ្ញុំ សូមប្រកាសថា</u>:***

១- នឹងបង់កំរៃអាជ្ញាប័ណ្ណ និងកំរៃផ្សេងៗទៀតដែលទាក់ទងនឹងការដាក់ពាក្យស្នើសុំនេះ

២- នឹងសុខចិត្តទទួលយល់ព្រមតាមគោលការណ៍ និងលក្ខខណ្ឌពាក់ព័ន្ធដែលមានចែងនៅក្នុងជូរទី៣ នៃតារាងខាងឆ្វេង ។

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

.................. ថ្ងៃទី .......... ខែ .................ឆ្នាំ២០០.......

ប្រធានក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម

ហត្ថលេខា

ឈ្មោះ ..................................................

# បញ្ជីរាយឈ្មោះវត្ថុធាតុដើម

សំរាប់ផលិត..........................................................................................

របស់ ក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម : ..........................................................

អាសយដ្ឋាន :..........................................................................................

| ល.រ | ឈ្មោះវត្ថុធាតុដើម | មុខសញ្ញាប្រើប្រាស់ | បរិមាណដែលប្រើគិតជា% នៃផលិតផលសំរេច | ផ្សេងៗ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |
| ៨ | | | | |
| ៩ | | | | |
| ១០ | | | | |
| ១១ | | | | |
| ១២ | | | | |
| ១៣ | | | | |
| ១៤ | | | | |
| ១៥ | | | | |
| ១៦ | | | | |
| ១៧ | | | | |

............. ថ្ងៃទី..........ខែ...............ឆ្នាំ.២០០

ប្រធានក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម

ហត្ថលេខា

## គំនូសបំព្រួញនៃខ្សែសង្វាក់ផលិតកម្ម

ក្នុងការផលិត ...................................................................................................................

របស់ ក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម :..............................................................................

អាសយដ្ឋាន:......................................................................................................................

............. ថ្ងៃទី.........ខែ..............ឆ្នាំ ២០០

ប្រធានក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម

ហត្ថលេខា

( អាចគូរលើក្រដាសផ្សេង ប្រសិនបើចាំបាច់ ប៉ុន្តែត្រូវតែមានការទទួលស្គាល់ពីប្រធានក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម )

## បញ្ជីរាយឈ្មោះ គ្រឿងចក្រ-ម៉ាស៊ីន និងឧបករណ៍ប្រើប្រាស់ក្នុងការផលិត

សំរាប់ផលិត.............................................................................................................

របស់ ក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម : .....................................................................

អាសយដ្ឋាន :.............................................................................................................

| ល.រ | ម៉ាស៊ីន និងឧបករណ៍ប្រើប្រាស់ ក្នុងការផលិត ផលិតផល | ថ្ងៃតម្លើង ម៉ាស៊ីន-ឧបករណ៍ | ថ្ងៃធ្វើការផ្ទៀងផ្ទាត់ ម៉ាស៊ីន-ឧបករណ៍ | ផ្សេងៗ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |
| ៨ | | | | |
| ៩ | | | | |
| ១០ | | | | |
| ១១ | | | | |
| ១២ | | | | |
| ១៣ | | | | |
| ១៤ | | | | |
| ១៥ | | | | |
| ១៦ | | | | |

............. ថ្ងៃទី..........ខែ..............ឆ្នាំ ២០០

ប្រធានក្រុមហ៊ុន/រោងចក្រ/សហគ្រាស/សិប្បកម្ម

ហត្ថលេខា

ឧបសម្ព័ន្ធ ២

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
Ministry of Industry, Mines and Energy
នាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា
Department of Industrial Standards of Cambodia

លេខ:
Number

ថ្ងៃចេញ:
Date of Issue

# វិញ្ញាបនប័ត្រផលិតផល
# Product Certificate

**នាយកដ្ឋានផ្តល់វិញ្ញាបនប័ត្រផលិតផលនេះដល់**
The Department hereby grants this Product Certificate to

ក្រុមហ៊ុន (Company) ..........................................................

អាសយដ្ឋាន (Address)..........................................................

ដើម្បីផលិត
to produce

ផលិតផល (Product)..........................................................

ម៉ាក (Trade Mark) ..........................................................

បានអនុលោមតាមស្តង់ដាកម្ពុជា (Complying with Cambodian Standard)
**CS 00X : 2005**

**ប្រធាននាយកដ្ឋានស្តង់ដាឧស្សាហកម្មកម្ពុជា**
Director of Department of Industrial Standards of Cambodia

វិញ្ញាបនប័ត្រនេះត្រូវបានផ្តល់ចំពោះក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម ដែលបានអនុវត្តទៅតាមការតំរូវនិងលក្ខខណ្ឌនៃប្រព័ន្ធចេញវិញ្ញាបនប័ត្រផលិតផល
This certificate is awarded subject to the Company's compliance with the prescribed requirements and conditions of the Product Certification Scheme

ឧបសម្ព័ន្ធ ៣

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

**ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
**Ministry of Industry, Mines and Energy**

# អាជ្ញាប័ណ្ណ

## សំរាប់ប្រើសញ្ញាបញ្ជាក់ផលិតផល
## License for the Use of Product Certification Mark

អាជ្ញាប័ណ្ណលេខ License No.: .................................................... ថ្ងៃចេញ Date of Issue: ..............................

យោងវិញ្ញាបនប័ត្រលេខ Referred Certificate Number: ........................ ថ្ងៃចេញ Date of Issue: ..............................

ក្រសួងឧស្សាហកម្ម រ៉ៃ និងថាមពល
Ministry of Industry, Mines and Energy

ផ្តល់ជូន Granted to:...................................ចាប់ពីពេលនេះទៅហៅថា **អ្នកកាន់អាជ្ញាប័ណ្ណ** Thereby called **Licensee**

អាសយដ្ឋានផលិតកម្ម Address: ..................................................

ចាប់ពីពេលនេះ អ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិប្រើសញ្ញាស្តង់ដាររបស់ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ដែលបានបង្ហាញនៅក្នុងជួរឈរទី១ សំរាប់ផលិតផលដែលមានឈ្មោះនៅក្នុងជួរឈរទី២ ដោយបានផលិតអនុលោមតាមស្តង់ដាដែលមាននៅក្នុងជួរឈរទី៤ នៃតារាងខាងក្រោម ។

| ផលិតផលដែលទទួលបានអាជ្ញាប័ណ្ណ Products for which the license is granted | | ប្រភេទ ឬ លក្ខណៈសំគាល់ផ្សេងៗទៀតរបស់ផលិតផល Type or other description of products | ស្តង់ដាយោង Referred Standard(s) | លក្ខខណ្ឌកំណត់ Specific conditions |
|---|---|---|---|---|
| សញ្ញាស្តង់ដា ISC<br>ISC Standard Mark<br>(1) | ផលិតផល , ម៉ាកផលិតផល<br>Product , Trade Mark<br>(2) | (3) | (4) | (5) |
| CS-00X:2005<br>00X/05 | | | | ១-អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៩ខែឧសភា ឆ្នាំ ២០០១ ស្តីពីស្តង់ដាឧស្សាហកម្មកម្ពុជា<br>២-ប្រកាសស្តីពីលក្ខខណ្ឌទូទៅនៃការផ្តល់អាជ្ញាប័ណ្ណសំរាប់ប្រើសញ្ញាបញ្ជាក់ផលិតផល<br>៣- កិច្ចព្រមព្រៀងនៃការប្រើសញ្ញា<br>៤- លក្ខខណ្ឌជាក់លាក់ |

ថ្ងៃផុតកំណត់ Date of Expiry : ....................

**រដ្ឋមន្ត្រី**
Minister

អាជ្ញាប័ណ្ណនេះត្រូវបានផ្តល់ចំពោះអ្នកកាន់អាជ្ញាប័ណ្ណដែលបានអនុវត្តទៅតាមការតំរូវនៃប្រព័ន្ធគុណភាពនិងលក្ខខណ្ឌដែលបានកំណត់
This License is awarded subject to the Licensee's compliance with the quality system requirements, terms and conditions